# ព្រឹត្តិបត្រប្រចាំត្រីមាសទី១

## ទឹកស្អាតសម្រាប់មនុស្សគ្រប់រូប

ខែមករា ដល់ ខែមីនា ឆ្នាំ២០២២

## បច្ចុប្បន្នភាពសមាគម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជនមិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

សមាគមបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយក្រុមអ្នកផ្គត់ផ្គង់ទឹកស្អាតឯកជនមួយក្រុមមានគ្នាប្រមាណជា ២០នាក់ ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង «អេម អេស អេម អ៊ី កម្ពុជា (MSME)» ឧបត្ថម្ភដោយទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងបានចុះបញ្ជីសមាគមជាផ្លូវការនៅក្រសួងមហាផ្ទៃ តាមសេចក្តីជូនដំណឹងលេខៈ ១០៧៧ សជណ របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០១២។ ក្រសួងមហាផ្ទៃចេញសេចក្តីប្រកាសលេខ: ២៩០១ ប្រក ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១ សម្រេចចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឡើងវិញក្នុង«បញ្ជីសមាគមសម្រាប់នីតិបុគ្គល» នៅក្រសួងមហាផ្ទៃ ដោយមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលស្ថិតនៅអគារ F ជាន់ទី២ បន្ទប់លេខ ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគមបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

គិតត្រឹមត្រីមាសទី១ ឆ្នាំ២០២២ សមាគមមានសមាជិកសរុបចំនួន ៣០០ស្ថានីយ / ក្រុមហ៊ុន កំពុងប្រតិបត្តិការនៅក្នុង ២៣ខេត្ត/ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះមានសមាជិកជាប្រតិបត្តិករផ្គត់ផ្គត់ទឹកស្អាតចំនួន ២៧០ស្ថានីយ និងសមាជិកជាក្រុមហ៊ុនផ្គត់ផ្គង់លើវិស័យទឹកស្អាតចំនួន ៣០ក្រុមហ៊ុន។

## ១. កិច្ចប្រជុំក្រុមប្រឹក្សាភិបាល

នៅក្នុងត្រីមាសទី១នេះ ក្រុមប្រឹក្សាភិបាលបានរៀបចំកិច្ចប្រជុំ មួយដងទាក់ទៅនឹងការដោះស្រាយបញ្ហារបស់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ចាន់ ណារី ដែលស្ថិតនៅភូមិជ្រៃធំ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ដែលមានបញ្ហាជាមួយក្រុមហ៊ុន កាស៊ីណូក្រោន (ការផ្គត់ផ្គង់ទឹកក្នុងតំបន់អាជ្ញាបណ្ណរបស់លោកស្រី ចាន់ ណារី)។

## ២. សន្និបាតសមាគម

ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ វេលាម៉ោង ១៣.០០ រសៀលដល់ម៉ោង ២១.០០ យប់ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានរៀបចំសន្និបាតប្រចាំឆ្នាំលើកទី១០ នៅភោជនីយដ្ឋានទន្លេបាសាក់២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម **អ៊ំ សុថា** រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ឧវបន) និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧវបន ជាប្រធានគណៈអធិបតី និងឯកឧត្តម **ឥន់ សុខជា** អគ្គនាយក នៃអគ្គនាយកដ្ឋានទឹកស្អាត ព្រមទាំងមន្ត្រីអមដំណើរ លោក **ស្រ៊ីន ពុទ្ធី** ប្រធាននាយកដ្ឋានទឹកស្អាតជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ និងក្រុមប្រឹក្សាភិបាលសមាគមទាំង៩រូប។




*រូបភាពទី១៖ សុន្ទរកថាបើកអង្គសន្និបាតសមាគមដោយ ឯកឧត្តម អ៊ំ សុថា រដ្ឋលេខាធិការ ក្រសួងឧវបន*

សន្និបាតនេះមានអ្នកចូលរួមមកពី ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ក្រុមហ៊ុន ធនាគារ មីក្រូហិរញ្ញវត្ថុ និងអង្គការដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិ សរុបចំនួន ២៧០នាក់ (ស្ត្រី ៥៨នាក់)។ ជាងនេះទៅទៀត អង្គសន្និបាតលើកទី១០ ប្រចាំឆ្នាំ២០២១ ទទួលបានការចូលរួមឧបត្ថម្ភពី៖

**ក. ក្រុមហ៊ុនដែលជាសមាជិកសមាគមចំនួន ១០(ដប់)ក្រុមហ៊ុន រួមមាន៖**

១. ក្រុមហ៊ុន ភ្នំពេញប្លាស្ទិច ប្រូដាក់

២. ក្រុមហ៊ុន ធីស៊ីយូ ប៉ូលី អេធីប្រាយ

៣. ក្រុមហ៊ុន ជី អ៊ី អឹម ខូអិលធីឌី

៤. សហគ្រាស អ៊ី-ផៅវ៉័ ស៊ីស៊ីអិល

៥. សហគ្រាស វ៉ើរ ផាតនឺរ (ខេមបូឌា) ឯ.ក

៦. ក្រុមហ៊ុន វ៉េធើមិុច ថេកណាឡូជី

៧. ក្រុមហ៊ុន ខេស៊ីអអាយ អ៊ិនជើណេសិនណាល ខូអបភើរេសិន ឯ.ក

៨. ក្រុមហ៊ុន ជីនីមិុច ខូអេលធីឌី

៩. ការិយាល័យតំណាង របស់ក្រុមហ៊ុន Fuji Electric Co., Ltd

១០. អ៊ីឌែមីតស៊ុ សេហ្សុង ម៉ាយក្រូហ្វាយនែន (ខេមបូឌា)

**ខ. ដៃគូសហការជាតិ និងអន្តរជាតិ ចំនួន ៣(បី)រួមមាន៖**

១. សមាគមទឹកអូស្ត្រាលី (AWA)

២. សមាគមអាជីវកម្មទឹកបរទេសនៃទីក្រុង Kitakyushu (KOWBA)

៣. ក្រុមហ៊ុន ISEA និង The Stone Family Foundation និង

**គ. ក្រុមហ៊ុនចំនួន ៥ (ប្រាំ) ដែលមិនមែនជាសមាជិកសមាគម រួមមាន៖**

១. ធនាគារ Phillip Bank

២. ធនាគារ FTB Bank

៣. ក្រុមហ៊ុន Hydro Scada Solution

៤. ក្រុមហ៊ុន HITACHI Zosen Cooperation

៥. ក្រុមហ៊ុន Water Tiger Solution



*រូបភាពទី២៖ រូបភាពអនុស្សាវរីយ៍នៅថ្ងៃសន្និបាតសមាគម*

## ៣. គម្រោង ហិរញ្ញវត្ថុសម្រាប់ទឹកស្អាត និងអនាម័យ (WASH-FIN)

### ៣.១. កិច្ចប្រជុំពិគ្រោះយោបល់ រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងសេវាករផ្គត់ផ្គង់ទឹកស្អាត

ថ្ងៃទី២៤ ខែមករា ឆ្នាំ២០២២ ក្រោមជំនួយឧបត្ថម្ភពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ USAID តាមរយៈគម្រោង WASH-FIN និងអង្គការវ៉េតជីអេតកម្ពុជា សមាគមបានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងសេវាករផ្គត់ផ្គង់ទឹកស្អាត នៅខេត្តកំពង់ស្ពឺ។ កិច្ចប្រជុំមានអ្នកចូលរួមសរុបចំនួន ៧៣នាក់ (ស្រី ១១នាក់) ក្រោមអធិបតីភាពឯកឧត្តម ជា វិសុទ្ធ ទីប្រឹក្សារបស់ក្រសួងឧបេន ។



*រូបភាពទី៣៖ កម្រងរូបភាពអនុស្សាវរីយ៍ ក្នុងកិច្ចប្រជុំ នៅខេត្តកំពង់ស្ពឺ*

### ៤.២. វគ្គបណ្តុះបណ្តាល

ថ្ងៃទី២០-២១ ខែមករា ឆ្នាំ២០២២ ក្រោមជំនួយឧបត្ថម្ភពីទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ USAID តាមរយៈគម្រោង WASH-FIN សមាគបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី «*ផែនការសុវត្ថិភាពទឹក*» ដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អានចំនួន ១២ស្ថានីយ និងមានអ្នកចូលរួមសរុប ១៣នាក់ (ស្រី ២នាក់)។




*រូបភាពទី៤៖ រូបភាពវគ្គបណ្តុះបណ្តាលស្តីពី «ផែនការសុវត្ថិភាពទឹក»*

## ៣.២. ការបិទបញ្ចប់ និងការឆ្លុះបញ្ចាំងគម្រោង WASH-FIN

ថ្ងៃទី១០-១១ ខែមីនា ឆ្នាំ២០២២ ក្រោមជំនួយឧបត្ថម្ភពី ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ USAID តាមរយៈគម្រោង (WASH-FIN) សមាគមបានរៀបចំសិក្ខាសាលារៀនសូត្រជាមួយភាគីពាក់ព័ន្ធ និងការឆ្លុះបញ្ចាំងចុងក្រោយ ក្នុងគោលបំណងឆ្លុះបញ្ចាំងពីសមិទ្ធិផលនានារបស់គម្រោង WASH-FIN នៅកម្ពុជា។



*រូបភាពទី៥៖ រូបភាពសិក្ខាសាលាបិទបញ្ចប់ និងការឆ្លុះបញ្ចាំងគម្រោង WASH-FIN*

ព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០២២ នៅភោជនីយដ្ឋានទន្លេបាសាក់ សមាគមបានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំង គម្រោង WASH-FIN ដែលអ្នកចូលរួមសរុបចំនួន ៤៧នាក់ (ស្រី ១០នាក់) ដែលមានសមាសភាពចូលរួមពីប្រតិបត្តិករ ២៩នាក់ បុគ្គលិកសមាគម ១០នាក់ បុគ្គលិកគម្រោង WASH-FIN ៨នាក់ និងតំណាងធនាគារ ១នាក់។

ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ នៅសណ្ឋាគារសាន់វេ សមាគមបានរៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងគម្រោងWASH-FIN ដែលអ្នកចូលរួមសរុបចំនួន ៥៣នាក់ (ស្រី ១៥នាក់) ដែលមានសមាសភាពចូលរួមពីតំណាងក្រសួងឧវបន ចំនួន ៣នាក់ តំណាងក្រសួងមហាផ្ទៃចំនួន ២នាក់ តំណាង គ.ជ.អ.បចំនួន ១នាក់ ដៃគូអភិវឌ្ឍន៍ចំនួន ៧នាក់ តំណាងធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៧នាក់ ប្រតិបត្តិករចំនួន ១៦នាក់ បុគ្គលិកគម្រោង WASH-FIN ៨នាក់ បុគ្គលិកសមាគម ៨នាក់ និងអ្នកបកប្រែចំនួន ១នាក់។



*រូបភាពទី៦៖ រូបភាពសិក្ខាសាលាបិទបញ្ចប់ និងការឆ្លុះបញ្ចាំងគម្រោង WASH-FIN*

## ៤. គម្រោង ការបង្កើននូវភាពធន់ នឹងការប្រែប្រួលអាកាសធាតុសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត (UNICEF)

ត្រីមាសទី១ ឆ្នាំ២០២២ ក្រោយពីបានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនផ្គត់ផ្គង់បំពង់ទឹកស្អាត ក្នុងគម្រោង *«ការបង្កើននូវភាពធន់នឹងការប្រែប្រួលអាកាសធាតុសម្រាប់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត»* ក្រុមហ៊ុនបានផ្គត់ផ្គង់បំពង់ទឹកស្អាតទៅស្ថានីយទឹកស្អាតសេកគង់បាត់ដឹង ស្ថានីយទឹកស្អាតក្រាំងចេក ស្ថានីយទឹកស្អាតវិនគារ និងស្ថានីយទឹកស្អាតវាលពង់។ បុគ្គលិកបច្ចេកទេសសមាគមក៏បានចុះត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ការពង្រីកបណ្តាញចែកចាយទឹកស្អាតដូចខាងក្រោម៖

ថ្ងៃ១៦ ខែមីនា ឆ្នាំ២០២២ បានចុះពិនិត្យ និងផ្ទៀងផ្ទាត់បណ្តាញចែកចាយទឹកស្អាត នៅស្ថានីផ្គត់ផ្គង់ទឹកស្អាត ក្រាំងចេក ដែលមានទីតាំងនៅឃុំក្រាំងចេក ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។



*រូបភាពទី៧៖ ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ក្រាំងចេក*

ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ បានចុះពិនិត្យ និងផ្ទៀងផ្ទាត់បណ្តាញចែកចាយទឹកស្អាត នៅស្ថានីយទឹកស្អាតវិនគាវ ដែលមានទីតាំងនៅ ឃុំបុរីជលសារ ស្រុកបុរីជលសារខេត្តតាកែវ។



*រូបភាពទី៨៖ សកម្មភាពជីកដីកប់ទុយទឹកស្អាត របស់ស្ថានីយទឹកស្អាតវិនគាវ*

ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ បុគ្គលិកបច្ចេកទេសសមាគម បានចុះត្រួតពិនិត្យ និងផ្ទៀងផ្ទាត់បំពង់បណ្តាញចែកចាយទឹកស្អាត នៅស្ថានីយផ្គត់ផ្គង់ទឹកស្អាត វាលពង់ ដែលមានទីតាំងនៅឃុំវាលពង់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។



*រូបភាពទី៩៖ សកម្មភាពតទុយទឹកស្អាត របស់ស្ថានីយទឹកស្អាតវាលពង់*

ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចំនួន ៣ស្ថានីយ បានកប់បណ្តាញបំពង់ទឹកស្អាតដែលមានប្រវែងសរុប ៣៩,៦៩៨ ម៉ែត្រ ក្នុងនោះមាន៖ ស្ថានីយផ្គត់ផ្គង់ទឹកស្អាតក្រាំងចេក ប្រវែង ១៤,១៨០ម៉ែត្រ ស្ថានីយផ្គត់ផ្គង់ទឹកស្អាតវាលពង់ ប្រវែង ៦,៨៦០ម៉ែត្រ និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតសេកគង់បាត់ដឹង ប្រវែង ១៨.៦៥៨ម៉ែត្រ។

ជាលទ្ធផលក្រោយពេលកប់បំពង់ទុយោរួចមក ស្ថានីយផ្គត់ផ្គង់ទឹកក្រាំងចេក បានតភ្ជាប់បណ្តាញទឹកស្អាតចំនួន ៧៣០គ្រួសារបន្ថែម ស្ថានីយទឹកស្អាតវាលពង់ បានតភ្ជាប់បណ្តាញទឹកស្អាតចំនួន ៥គ្រួសារបន្ថែម។ ប្រតិបត្តិករទាំងអស់ រំពឹងថា នឹងបង្កើនតំណគ្រួសារថ្មីនៅត្រីមាសបន្ទាប់។

ជាងនេះទៅទៀត ក្នុងត្រីមាសទី១ គម្រោងបានខួងអណ្តូងបានចំនួន ៧អណ្តូង (ស្ថានីយផ្គត់ផ្គង់ទឹកស្អាតប៉េងហុង បានចំនួន ៤អណ្តូង និងស្ថានីយផ្គង់ទឹកស្អាតសេកគង់បាត់ដឹង បានចំនួន ៣អណ្តូង) ដើម្បីជួយបង្កើនបរិមាណប្រភពទឹកសម្រាប់ស្ថានីយទាំងពីរផលិត និងចែកចាយជូនដល់ប្រជាពលរដ្ឋក្នុងតំបន់ដែលរងគ្រោះដោយគ្រោះរាំងស្ងួត។

## ៥. គម្រោងការពង្រឹងគណនេយ្យភាពរបស់សេវាករផ្គត់ផ្គង់ទឹកស្អាត ដើម្បីលើកកម្ពស់សេវាកម្មទឹកស្អាត(WaterAid)

### ៥.១. កិច្ចប្រជុំផ្ទះបញ្ចាំងការអនុវត្តគម្រោង

នៅត្រីមាសទី១ សមាគមបានរៀបចំកិច្ចប្រជុំផ្ទះបញ្ចាំងការអនុវត្តគម្រោង«ការពង្រឹងគណនេយ្យភាពរបស់សេវាករផ្គត់ផ្គង់ទឹកស្អាត ដើម្បីលើកកម្ពស់សេវាកម្មទឹកស្អាត» ចំនួន ២ដង ក្រោមជំនួយឧបត្ថម្ភអង្គការវ៉តធឺអេតកម្ពុជា (WaterAid) នៅក្រុមហ៊ុនលង្វែក ឌីវេឡុបម៉ិន វ៉តធើរសើបផ្លាយ ឯ.ក. និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតបែកចាន។ សមាសភាពអ្នកចូលរួមអញ្ជើញមកពី តំណាងមន្ទីរឧវបន តំណាងរដ្ឋបាលស្រុក មេឃុំ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត បុគ្គលិកអង្គការវ៉តធឺអេតកម្ពុជា និងបុគ្គលិកសមាគម។



*រូបភាពទី១០៖ បទបង្ហាញផ្សព្វផ្សាយគម្រោងដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត នៅស្ថានីយទឹកស្អាតបែកចាន*

### ៥.២. វគ្គបណ្តុះបណ្តាល

ថ្ងៃទី១០-១១ ខែកុម្ភៈ ឆ្នាំ២០២២ ក្រោមជំនួយឧបត្ថម្ភពីអង្គការវ៉តធឺអេតកម្ពុជា សមាគមបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«បច្ចេកទេសនៃការផលិតទឹកស្អាត និងការតេស្តគុណភាពទឹកស្អាត» និង «តួនាទី និងការទទួលខុសត្រូវលើសេវាកម្មផ្គត់ផ្គង់ទឹកស្អាត» នៅសាលាស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដែលមានអ្នកចូលរួមសរុបចំនួន ២៤នាក់ (ស្រី៨ នាក់)។ សមាសភាពអ្នកចូលរួមអញ្ជើញមកពីមន្ទីរ ឧវបន ខេត្តកំពង់ស្ពឺ ចំនួន ៣នាក់ រដ្ឋបាលស្រុកចំនួន ៥នាក់ ក្រុមប្រឹក្សាឃុំចំនួន ៦នាក់ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចំនួន ៨នាក់ និងអ្នកសម្របសម្រួលពីសមាគមចំនួន ២នាក់។



*រូបភាពទី១១៖ ការធ្វើតេស្តសម្អាតទឹកនៅសាលាស្រុកសំរោងទង ខេត្តកំពង់ស្ពឺ*

### ៥.៣. វគ្គបង្វឹក

នៅត្រីមាសនេះ សមាគមក៏បានសហការជាមួយរដ្ឋបាលស្រុកកំពង់ត្រឡាច ដើម្បីរៀបចំវគ្គបង្វឹកស្តីពី «ការតេស្តគុណភាពទឹកស្អាត» នៅឃុំទាំង ១០របស់ស្រុកកំពង់ត្រឡាច ក្រោមការឧបត្ថម្ភពីអង្គការវ៉តជីអេតកម្ពុជា។ អ្នកចូលរួមសរុបចំនួន ៨៥នាក់ (ស្រី ២២នាក់) ដែលមានសមាសភាពចូលរួមពីតំណាងមន្ទីរឧបន ខេត្តកំពង់ឆ្នាំង មន្ត្រីរដ្ឋបាលស្រុកកំពង់ត្រឡាច មេឃុំ និងសមាជិកក្រុមប្រឹក្សាឃុំ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។



*រូបភាពទី១២៖ វគ្គបង្វឹកស្តីពី «ការតេស្តគុណភាពទឹកស្អាត»*

ក្រុមប្រឹក្សាឃុំមានប្រសាសន៍ថា *«ខ្ញុំពិតជាសប្បាយរីករាយខ្លាំងណាស់ដែលបានចូលរួមក្នុងការបង្វឹកនេះ ទោះមានរយៈពេលខ្លី តែខ្លឹម ព្រោះខ្ញុំកាន់តែយល់ច្បាស់ពីគុណភាពទឹកស្អាត និងដំណើរការនៃការផលិតទឹកស្អាត។ ជាងនេះទៅទៀត ខ្ញុំមានទំនុកចិត្តខ្លាំងក្នុងការពន្យល់ទៅប្រជាពលរដ្ឋពីគុណភាព និងសេវាកម្មទឹកស្អាត»។*

## ៦. ការពង្រឹងមូលដ្ឋានគ្រឹះសម្រាប់សន្តិសុខទឹក នៅកម្រិតស្រុកក្នុងប្រទេសកម្ពុជា Water-Aid

### ៦.១. សិក្ខាសាលារៀបចំផែនការគ្រប់គ្រងធនធានទឹកប្រកបដោយបរិយាប័ន្នរបស់ស្រុកសាមគ្គីមានជ័យ

ត្រីមាសទី១ ឆ្នាំ២០២២ គម្រោងបានធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រងធនធានទឹកប្រកបដោយបរិយាប័ន្ន សម្រាប់ស្រុកសាមគ្គីមានជ័យ ដោយផ្អែកលើស្ថានភាពជាក់ស្តែងបច្ចុប្បន្ន និងជំរុញឱ្យមានការអនុវត្តសកម្មភាពរួមគ្នា និងការចូលរួមរបស់អ្នកពាក់ព័ន្ធសំខាន់ៗ ជាពិសេសការចូលរួមដ៏មានអត្ថន័យរបស់តំណាងក្រុមជនងាយរងគ្រោះ និងស្ត្រី ក្នុងការគ្រប់គ្រងធនធានទឹក និងវិស័យទឹកស្អាត និងអនាម័យ។



*រូបភាពទី១៣៖ ការរៀបចំផែនការរបស់ឃុំ*

## ៧. គម្រោងឧបត្ថម្ភធនលើថ្លៃភ្ជាប់ទឹកសម្រាប់គ្រួសារក្រីក្រ (EMW)

ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ សមាគមបានរៀបចំកិច្ចប្រជុំដើម្បីណែនាំគម្រោងបដិភាគគ្រួសារក្រីក្រទៅដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ចំនួន ៥ស្ថានីយ (សរុបមាន ៨នាក់) ដែលបានជ្រើសរើសបន្ថែម។



*រូបភាពទី១៤៖ ការធ្វើបទបង្ហាញអំពីគម្រោងបដិភាគគ្រួសារក្រីក្រ ដល់ប្រតិបត្តិករទឹកស្អាត នៅការិយាល័យសមាគម*

ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២២ ក្រោមជំនួយឧបត្ថម្ភពី អង្គការលោកខាងលិចជួបលោកខាងកើត (EMW) សមាគមបានរៀបចំកិច្ចប្រជុំ *«ផ្សព្វផ្សាយដល់សហគមន៍អំពីការប្រើប្រាស់ទឹកស្អាត»* ស្ថិតនៅភូមិទី៣ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងមានប្រជាពលរដ្ឋចូលរួមសរុបចំនួន ៧០នាក់ (ស្រី ៥០នាក់)។

## ៨. គម្រោងសិក្សារៀបចំព័ត៌មានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត សម្រាប់ភេទុនកម្ចី Water.org




នៅក្នុងត្រីមាសនេះ សមាគមបានប្រជុំពិភាក្សាជាមួយក្រុមការងារក្រុមហ៊ុន E-Water និងអង្គការ Water.org ដើម្បីរៀបចំកម្រងសំណួរ និងប្រព័ន្ធព័ត៌មានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ដើម្បីចងក្រងទិន្នន័យអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត សម្រាប់ឱ្យប្រតិបត្តិករងាយក្នុងការរកទុនកម្ចីពីស្ថាប័នហិរញ្ញវត្ថុ។

## ៩. គម្រោងសម្ព័ន្ធភាពដើម្បីអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌ ( Aide et Action )

នៅក្នុងត្រីមាសទី១នេះ សមាគមបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយគម្រោងតាមប្រព័ន្ធអនឡាញចំនួន ២ ដងក្នុងគោលបំណង៖

- ណែនាំអំពីទិដ្ឋភាពទូទៅនៃគម្រោង និងផែនការសកម្មភាពរបស់គម្រោង
- ស្វែងរកការគាំទ្រ និងកិច្ចសហការពីអាជ្ញាធរមូលដ្ឋាន ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងអ្នកពាក់ព័ន្ធនានាដើម្បីអនុវត្តគម្រោងឱ្យមានប្រសិទ្ធភាព។

- ➢ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ សមាគមបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយគម្រោង«គម្រោងសម្ព័ន្ធភាពដើម្បីអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌» សម្រាប់ខេត្តកំពត ដែលមានអ្នកចូលរួមពី៖ តំណាងក្រសួង និង មន្ទីរ ឧវបន តំណាងមន្ទីរអភិវឌ្ឍន៍ជនបទ តំណាងមន្ទីរអប់រំ យុវជន និងកីឡា តំណាងរដ្ឋបាលខេត្ត តំណាងអភិបាលស្រុក ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន តំណាងមកពីអង្គការ Aide et Action និងបុគ្គលិកសមាគម សរុបចំនួន ២៦នាក់។
- ➢ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ សមាគមបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយគម្រោង«គម្រោងសម្ព័ន្ធភាពដើម្បីអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌» សម្រាប់ខេត្តកែប ខេត្តព្រះសីហនុ និងខេត្តកោះកុង ដែលមានសមាសភាពអ្នកចូលរួមមកពី ក្រសួង និងមន្ទីរឧវបន តំណាងរដ្ឋបាលខេត្ត ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍសហគមន៍ខេត្ត តំណាងរដ្ឋបាលស្រុក តំណាងមន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរអប់រំ យុវជន និងកីឡា ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងបុគ្គលិកសមាគម ដែលមានអ្នកចូលរួមសរុបទាំងអស់ចំនួន ៤៧នាក់។




## ១០. កម្មវិធីវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i)

ក្នុងត្រីមាសទី១ ក្រោមកិច្ចសហការរបស់កម្មវិធីវិនិយោគក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ (3i) សមាគមបានរៀបចំសិក្ខាសាលាស្តីពី *«ការបង្ហាញពីផែនទីអន្តរកម្ម PIP សម្រាប់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត»* ចំនួន ៤លើកដូចខាងក្រោម

- ➢ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០២២ នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ សម្រាប់ខេត្តព្រៃវែង ស្វាយរៀង តាកែវ កណ្ដាល និងរាជធានីភ្នំពេញ មានអ្នកចូលរួមចំនួន ៥៣នាក់ (ស្រី ១០នាក់)។



*រូបភាពទី១៥៖ ការធ្វើបទបង្ហាញអំពីគម្រោងដោយ លោកស្រី ហួត ណារី នៅសណ្ឋាគារសាន់វេ*

➢ ថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ នៅសណ្ឋាគារផ្ទេរថ្មី ខេត្តព្រះសីហនុ សម្រាប់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតមកពីខេត្តកំពុងស្ពឺ ខេត្តកែប ខេត្តកំពត ខេត្តកោះកុង និងខេត្តព្រះសីហនុ។ សិក្ខាសាលាមានអ្នកចូលរួមចំនួនសរុប ២៧នាក់ (ស្រី ៧នាក់) មកពី ១១ស្ថានីយ និងតំណាង មីក្រូហិរញ្ញវត្ថុ អេ អឹម ខេ និង មីក្រូហិរញ្ញវត្ថុ ISC។

➢ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ នៅសណ្ឋាគារ លី ជី ស្ថិតនៅក្នុង ភូមិអូឬស្សី សង្កាត់អូឬស្សី ក្រុងក្រចេះ ខេត្តក្រចេះ ដែលមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចូលរួមចំនួន ២២ស្ថានីយ មកពីខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តមណ្ឌលគិរី និងប្រជាពលរដ្ឋចូលរួមសរុបទាំងអស់ចំនួន៤០ នាក់ ស្រី១១ នាក់។



*រូបភាពទី១៦៖ ការថតរូបអនុស្សាវរីយ៍ ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាល នៅសណ្ឋាគារផ្ទេរថ្មី*

➢ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២ នៅសណ្ឋាគារ ក្លាស់ស៊ី & ស្ប៉ា ស្ថិតនៅក្នុង ភូមិរំចេក សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ដែលមានប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចូលរួមចំនួន ២៨នាក់ មកពីខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ សរុបទាំងអស់ចំនួន៤៣ នាក់ (ស្រី៦ នាក់)។



*រូបភាពទី១៧៖ ការធ្វើបទបង្ហាញអំពីគម្រោងដោយលោកស្រី ហួត ណារី នៅសណ្ឋាគារភ្លាស៊ី ខេត្តបាត់ដំបង*

## ១១. កិច្ចសហការជាតិ

ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានសហការជាមួយមន្ទីរឧរបន ខេត្តតាកែវ និងរដ្ឋាបាលស្រុកទ្រាំង ខេត្តតាកែវ បានសម្របសម្រួល និងដោះស្រាយវិវាទប្រតិបត្តិករផ្គត់ផ្គងទឹកស្អាត នៅសាលាស្រុកទ្រាំង ដោយមានការអញ្ជើញចូលរួមពី **លោក កេត ព្រុង** ប្រធានមន្ទីរឧរបន ខេត្តតាកែវ និងសហការី លោក ស៊ុត ខឿន នាយករដ្ឋាបាលសាលាស្រុកទ្រាំង លោក សៀ សេងហ៊ាប ក្រុមប្រឹក្សាភិបាលសមាគម លោក លឹម មិញ នាយកប្រតិបត្តិសមាគម និងលោក លោកស្រី មេឃុំ និងក្រុមប្រឹក្សាភិបាលឃុំ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។ សរុបអ្នកចូលរួមមាន ១៧ នាក់ (ស្រី ៤នាក់)។ ជាលទ្ធផល ប្រតិបត្តិករផ្គត់ផ្គងទឹកស្អាតទាំងពីរបានយល់ព្រម និងឯកភាពបញ្ចប់វិវាទរវាងគ្នា និងគ្នាតាមស្មារតីសមាជិកសមាគម។




*រូបភាពទី១៨៖ កិច្ចប្រជុំសម្របសម្រួលទំនាស់សមាជិក នៅសាលាស្រុកទ្រាំង ខេត្តតាកែវ*

## ១២. កិច្ចសហការអន្តរជាតិ

សមាគមបានសម្របសម្រួលក្នុងការរៀបចំសិក្ខាសាលាតាមប្រព័ន្ធអនឡាញ ស្តីពីប្រព័ន្ធទឹកស្អាត និងអនាម័យ កម្ពុជា-ជប៉ុន ថ្ងៃទី ២៧-២៨ ខែមករា ឆ្នាំ២០២២

